**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៥២២/១៦ គ.ជ.ប

# សេចក្តីអំពាវនាវ

## ចំពោះប្រជាពលរដ្ឋខ្មែរ ដែលកំពុងបំពេញបេសកកម្ម និងធ្វើការនៅក្រៅប្រទេស

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) មានកិត្តិយសសូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងបំពេញបេសកកម្ម ធ្វើការ ឬសិក្សានៅក្រៅប្រទេសទាំងអស់ឱ្យបានជ្រាបថា ៖

១. ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅតាមសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដែលបើកធ្វើការជារៀងរាល់ថ្ងៃ (ក្នុងម៉ោងធ្វើការ) គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ។

២. ការចុះឈ្មោះបោះឆ្នោតនេះ គឺជាការចុះឈ្មោះបោះឆ្នោតថ្មីឡើងវិញទាំងស្រុង ដើម្បីរៀបចំបញ្ជីបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ ។

៣. ដើម្បីចុះឈ្មោះបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា និងមានអាយុយ៉ាងតិច ១៨ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត ហើយត្រូវមកចុះឈ្មោះដោយផ្ទាល់ ។

៤. ប្រជាពលរដ្ឋខ្មែរ ដែលមានបំណងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ដូចបានបញ្ជាក់ជូនខាងលើ សូមប្រញាប់មកចុះឈ្មោះបោះឆ្នោតឱ្យបានទាន់ពេលវេលាតាមកាលបរិច្ឆេទដែលបានកំណត់ ។

**សូមបញ្ជាក់ថា ៖** ***បើបងប្អូនមិនបាននៅចុះឈ្មោះបោះឆ្នោតទេនោះ នៅថ្ងៃបោះឆ្នោតនឹងមិនអាចបោះឆ្នោតបានទេ ។***

អាស្រ័យហេតុនេះ គ.ជ.ប សូមអំពាវនាវបងប្អូនប្រជាពលរដ្ឋខ្មែរ អញ្ជើញមកចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់គ្នា ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក